ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៦៩
ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩

សាលដីកា
លេខ ៦៣ "VI"
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥- លោក [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១៤៩ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៩ របស់លោក [redacted] សិដ្ឋហេង ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៥ ក្រIV "ណ" ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ដែលមានៈ

**-ជនជាប់ចោទ**

១-ឈ្មោះ [redacted] ថេត ភេទប្រុស កើតឆ្នាំ១៩៨០ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តកំពង់ធំ។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់។ ទោសពីមុនគ្មាន (ដើមបណ្តឹងសាទុក្ខ)



Scanned with CamScanner

២-ឈ្មោះ [redacted] អឿន ភេទប្រុស កើតឆ្នាំ១៩៨៦ ជាតិខ្មែរ មុខរបរជាងភ្លើង ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន។ (ដើមបណ្តឹងសាទុក្ខ)

៣-ឈ្មោះ [redacted] ឡែន ភេទប្រុស កើតឆ្នាំ១៩៧៨ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន។ (ដើមបណ្តឹងសាទុក្ខ)

៤-ឈ្មោះ [redacted] វី ភេទប្រុស កើតឆ្នាំ១៩៧៨ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុនគ្មាន។ (ដើមបណ្តឹងសាទុក្ខ)

-មានមេធាវីការពារសិទ្ធិ លោក [redacted] សឹង្ហហេង

**ជាប់ចោទពីបទ:** ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចភូមិពង្រលឹង ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហាន ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន នៅភូមិ [redacted] ខេត្តកំពង់ធំ។

<u>អំពីអង្គហេតុ</u>

កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ នៅចំណុចទំនប់អាងទឹកខាងកើត ភូមិពង្រលឹង ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ជនជាប់ចោទឈ្មោះ [redacted] ថេត ឈ្មោះ [redacted] អឿន ឈ្មោះ [redacted] ឡែន និងឈ្មោះ [redacted] វី បានធ្វើសកម្មភាពយកពូថៅកាប់ទៅលើឈ្មោះ [redacted] សំណាង ពីក្រោយ បណ្តាលឱ្យត្រូវចំក្បាលផ្នែកខាងក្រោយចំនួន ៣ ពូថៅ របួសប្រវែង បី ស.ម ហើយនាំគ្នាលើកទម្លាក់ចូលក្នុងទឹកស្រះ ហើយរត់គេចខ្លួន រហូតដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ទើបសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៧ (ង) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ផ្តន្ទាទោសលើ៖

ក.ជនជាប់ចោទឈ្មោះ [redacted] ថេត ភេទប្រុស អាយុ៣៦ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ

ខ.ជនជាប់ចោទឈ្មោះ [redacted] អឿន ភេទប្រុស អាយុ២៨ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ

គ.ជនជាប់ចោទឈ្មោះ [redacted] ឡែន ភេទប្រុស អាយុ៣៨ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ

ឃ.ជនជាប់ចោទឈ្មោះ [redacted] វី ភេទប្រុស អាយុ៣៥ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ

ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេល ២៥ (ម្ភៃប្រាំ) ឆ្នាំ



Scanned with CamScanner

ពីបទ **ឃាតកម្មគិតទុកជាមុន** តាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងស្ថានសម្រាលតាមមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិពង្រលីង ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣។

២.សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី១១ ខែកក្កដា, ថ្ងៃទី២២ ខែវិច្ឆិកា និងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៧ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទ ទាំងបួននាក់ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៣៥ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] រី ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ (ង) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់សាលាខេត្តកំពង់ធំ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] អឿន ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ (ង) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់សាលាខេត្តកំពង់ធំ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៣៧ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ចេត ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ (ង) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់សាលាខេត្តកំពង់ធំ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៣៨ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ឡឿន ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៧ (ង) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់សាលាខេត្តកំពង់ធំ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣៥ ក្រIV “ណ” ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៥ លេខ ៣៦ លេខ ៣៧ និងលេខ ៣៨ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៧ របស់ជនជាប់ចោទឈ្មោះ សឿង រី ឈ្មោះ [redacted] អឿន ឈ្មោះ [redacted] ឡឿន និងឈ្មោះ [redacted] ចេត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៧ (ង) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការ។

៣-បន្តការឃុំខ្លួនជនជាប់ចោទទាំងបួនរូប តាមច្បាប់។

សាលដីកានេះ ធ្វើការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទទាំងបួនរូប ប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ ទុកសិទ្ធិឱ្យប្តឹងសាទុក្ខ តាមកំណត់ច្បាប់។



Scanned with CamScanner

-បានឃើញ បណ្តឹងសាទុក្ខលេខ ១៤៩ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ របស់លោក [redacted] សឹង្ហហេង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថេត, ឈ្មោះ [redacted] អឿង,ឈ្មោះ [redacted] ឡែន និងឈ្មោះ [redacted] វី បានប្តឹងមិនសុខចិត្តនិងសាលដីកាព្រហ្មទណ្ឌលេខ ៣៥ ក្រIV "ណា" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា នៅតុលាការអង្គសេចក្តីជនជាប់ចោទទាំងនោះបានឆ្លើយដោះសារថា ពួកខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងផ្តន្ទាទោសរបស់តុលាការអង្គសេចក្តីឡើយ។ តំណាងមហាអយ្យការឃើញថា ការឆ្លើយដោះសារនោះមិនមានមូលហេតុដូចក្នុងមាត្រា៤១៩ ដែលនាំឱ្យតុលាការកំពូលពិចារណាឡើយ។

ទទួលបណ្តឹងសាទុក្ខលេខ១៤៩ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ របស់លោក [redacted] សឹងហេង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថេត , [redacted] អឿន , [redacted] ឡែន និងឈ្មោះ [redacted] វី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ដោយខុសទៅនឹងគតិច្បាប់។

-ជនជាប់ចោទឈ្មោះ [redacted] ថេត បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ខ្លួនមិនបានប្រព្រឹត្តអំពើសម្លាប់ជនរងគ្រោះឈ្មោះ សំណាង [redacted] សំណាង)

សំណូមពរៈ សុំឱ្យតុលាការកំពូលសម្រេចលើកលែងការចោទប្រកាន់មកលើខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] អឿន បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ខ្លួនមិនបានប្រព្រឹត្តអំពើសម្លាប់ជនរងគ្រោះឈ្មោះ សំណាង [redacted] សំណាង)

សំណូមពរៈ សុំឱ្យតុលាការកំពូលសម្រេចលើកលែងការចោទប្រកាន់មកលើខ្លួន

-ជនជាប់ចោទឈ្មោះ [redacted] ឡែន បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ខ្លួនមិនបានប្រព្រឹត្តអំពើសម្លាប់ជនរងគ្រោះឈ្មោះ សំណាង [redacted] សំណាង)

សំណូមពរៈ សុំឱ្យតុលាការកំពូលសម្រេចលើកលែងការចោទប្រកាន់មកលើខ្លួន

-ជនជាប់ចោទឈ្មោះ [redacted] វី បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ខ្លួនមិនបានប្រព្រឹត្តអំពើសម្លាប់ជនរងគ្រោះឈ្មោះ សំណាង [redacted] សំណាង)

សំណូមពរៈ សុំឱ្យតុលាការកំពូលសម្រេចលើកលែងការចោទប្រកាន់មកលើខ្លួន

-លោកមេធាវី [redacted] សឹង្ហហេង ការពារក្តីឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ពាក់ព័ន្ធអង្គហេតុតាំងពីមន្ត្រីថ្នាក់ក្រោមមកឃើញថា អង្គហេតុមានការភ័ន្តច្រឡំការស្លាប់របស់ជនរងគ្រោះ៣ឆ្នាំមុន លុះដល់៣ឆ្នាំក្រោយទើបមានចាប់កូនក្តីខ្លួនតាមការយល់សុបិន្ត នៅពេលសាលាដំបូងចាប់កូនក្តីខ្លួនមកកូនក្តីខ្លួនមិនដែរឆ្លើយថាប្រព្រឹត្តទេ។ ហើយប្រពន្ធជនរងគ្រោះក៏បានមកដកពាក្យបណ្តឹង គឺគាត់ប្តឹងអ្នកផ្សេងមិនមែនកូនក្តីខ្លួនទេ។



Scanned with CamScanner

សំណូមពរ៖ សុំឱ្យក្រុមប្រឹក្សាមេត្តាសម្រេចបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិភាក្សា ពិចារណា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៤៩ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ របស់មេធាវី [redacted] សីង្ហហេង ជាអ្នកតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ថេត, [redacted] អឿន, [redacted] ឡៃ្បន និងឈ្មោះ [redacted] វី ក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌលេខ ៣៥ ក្រIV "ណ" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , ៤១៨ , ៤២០ និងមាត្រា ៤២២ ត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់តំណាងមហាអយ្យការអមតុលាការកំពូលលើកឡើងថា បណ្តឹងសាទុក្ខលេខ ១៤៩ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ របស់មេធាវី [redacted] សីង្ហហេង ជាអ្នកតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ថេត, [redacted] អឿន, [redacted] ឡៃ្បន និងឈ្មោះ [redacted] វី ក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌលេខ ៣៥ ក្រIV "ណ" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សមស្របតាមចំណុចសំអាងហេតុទី១ ខាងលើនេះរបស់តុលាការកំពូលដែរ ។

៣-យល់ឃើញថា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា នៅចំពោះមុខតុលាការអង្គសេចក្តី ជនជាប់ចោទទាំង ៤ នាក់នោះ បានឆ្លើយដោះសារថា ពួកខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងការផ្តន្ទាទោសរបស់តុលាការអង្គសេចក្តីឡើយ។ ការឆ្លើយដោះសារនោះមិនមានមូលហេតុដូចក្នុងមាត្រា៤១៩ (នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដែលនាំឱ្យតុលាការកំពូលពិចារណាឡើយ និងបានប្តឹងសុំឱ្យតុលាការកំពូលតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៥ ក្រIV"ណ" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល។ នាពេលសវនាការរបស់តុលាការកំពូល តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ដោយមានខ្លឹមសារ



Scanned with CamScanner

ការពារនូវសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនដែរ ។ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការនេះ តុលាការកំពូលពិចារណាឃើញថា មិនមានមូលដ្ឋានផ្អែកលើអង្គហេតុ ទម្ងន់នៃភស្តុតាងដាក់បន្ទុក និងអង្គច្បាប់សមស្របនោះទេ ។ ដោយហេតុថា តុលាការអង្គហេតុទាំងពីរថ្នាក់ គឺសាលាដំបូងខេត្តកំពង់ធំ ក៏ដូចជាសាលាឧទ្ធរណ៍ភ្នំពេញដែរ ដែលបានសម្រេចតម្កល់សាលក្រមសម្រេចរបស់សាលាដំបូងដែលមានសំអាងតែទៅលើភស្តុតាងចចាមអារ៉ាម និងភស្តុតាងប្រយោលប៉ុណ្ណោះ។ ក្នុងចំណោមភស្តុតាងដែលបានលើកជាមូលដ្ឋានសំអាងក្នុងការដាក់បន្ទុកលើជនជាប់ចោទទាំង ៤ នាក់ ពីបទធ្វើឃាតកម្មគិតទុកជាមុននោះ។ សូម្បីតែសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ក៏បានបង្ហាញពីភាពមិនច្បាស់លាស់នៃភស្តុតាងដាក់បន្ទុកលើជនជាប់ចោទទាំង ៤ នាក់ដែរ ដោយតំណាងមហាអយ្យការ បានលើកឡើងថា "ជនជាប់ចោទបានឆ្លើយបដិសេធ ហើយសាក្សីដែលបានឆ្លើយបំភ្លឺ ពុំមានសាក្សីណាមួយបានឃើញច្បាស់ទេ។ ហេតុនេះ គប្បីក្រុមប្រឹក្សាពិនិត្យ សម្រេចក្រោយកិច្ចពិភាក្សាដេញដោល" ។ នៅក្នុងកំណត់ហេតុនៃកិច្ចពិភាក្សាដេញដោលដំណើរការសវនាការរបស់សាលាឧទ្ធរណ៍ក៏មិនបានលេញចេញនូវអង្គហេតុ ឬភស្តុតាងដាក់បន្ទុកថ្មី ឬដាក់បន្ទុកបន្ថែមនោះឡើយ។ ការនេះក៏បានបង្ហាញឱ្យឃើញថា ក្នុងរឿងក្តីនេះវាស្ថិតនៅក្នុងកម្រិតវិមតិសង្ស័យដែលត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ ស្របតាមបទប្បញ្ញត្តិមាត្រា ៣៨ ត្រង់កថាខណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិមាត្រា៣៥១ ត្រង់កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-យល់ឃើញថា នាពេលសវនាការនៅចំពោះមុខតុលាការកំពូល ជនជាប់ចោទទាំង ៤ នាក់ សុទ្ធតែបានឆ្លើយប្រកែកថា ខ្លួនមិនបានប្រព្រឹត្តអំពើសម្លាប់ជនរងគ្រោះឈ្មោះ សំណាង [redacted] សំណាង) ដូចការចោទប្រកាន់ឡើយ និងសុំឱ្យតុលាការកំពូលសម្រេចលើកលែងការចោទប្រកាន់លើរូបខ្លួន ។ ចម្លើយនេះរបស់ជនជាប់ចោទទាំង ៤ នាក់ ស្របទៅនឹងចម្លើយរបស់ពួកគាត់បានឆ្លើយចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចៅក្រមស៊ើបសួរ ឆ្លើយចំពោះមុខអង្គសវនាការរបស់តុលាការសាលាដំបូងខេត្តកំពង់ធំ និងចម្លើយនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ ជាហេតុនាំឱ្យតុលាការកំពូលគប្បីលើកយកចម្លើយរបស់ជនជាប់ចោទទាំង ៤ នាក់នេះ មកពិនិត្យ ពិចារណា វិនិច្ឆ័យជារួមជាមួយនឹងភស្តុតាងផ្សេងទៀត ដែលតុលាការអង្គហេតុទាំងពីរថ្នាក់បានលើកយកមកពិនិត្យ ពិចារណា និងកំណត់ថា វាជាភស្តុតាងដាក់បន្ទុកលើជនជាប់ចោទទាំង ៤ នាក់ និងបានប្រកាសពីពិរុទ្ធភាព សម្រេច និងប្រកាសទោសលើជនជាប់ចោទទាំង ៤ នាក់ ពីបទឃាតកម្មគិតទុកជាមុន ។

៥-យល់ឃើញថា តាមខ្លឹមសារនៃសារនាការពារ ក៏ដូចជាសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់មេធាវីការពារក្តីឱ្យជនជាប់ចោទដែរ។ មេធាវីការពារជនជាប់ចោទបានលើកឡើងអះអាងថា កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ វេលាល្ងាច មានការដាក់ពាក្យប្តឹងបរិហារពីអញ្ញត្រជន លើករណីឃាតកម្មលើជនរងគ្រោះ



Scanned with CamScanner

ឈ្មោះ [redacted] សំណាង ដោយជនរងគ្រោះត្រូវជនមិនស្គាល់មុខ [អញ្ញត្រជន] សម្លាប់ ដោយជនរងគ្រោះត្រូវបានជនល្មើសកាប់ដោយពូថៅត្រូវចំក្បាល ផ្នែកខាងក្រោយចំនួន ៣ ពូថៅ និងត្រូវបានជនល្មើសអូសទម្លាក់ចូលក្នុងស្រះទឹក ។ រយៈពេល ៣ ឆ្នាំក្រោយពីករណីមនុស្សឃាតនោះបានកើតឡើង ក្រោយពីការស៊ើបអង្កេតអស់រយៈពេលយ៉ាងយូរ និងសំអាងលើ សម្ដីប្រជាពលរដ្ឋថា "មានអ្នកយល់សប្តិ" ទើបសមត្ថកិច្ចនគរបាលយុត្តិធម៌ខេត្តកំពង់ធំឈានដល់កំណត់មុខសញ្ញាសង្ស័យមកលើកូនក្ដីរបស់ខ្លួនទាំង ៤ នាក់ រួចចាប់ផ្ដើមបង្កសំណុំរឿង និងបានចាប់ឃាត់ខ្លួនកូនក្ដីរបស់ខ្លួនទាំង ៤ នាក់ បញ្ជូនទៅសាលាដំបូងខេត្តកំពង់ធំ ។ ក្នុងនីតិវិធីស៊ើបអង្កេត ស៊ើបសួរ ពិភាក្សាដេញដោលនៅចំពោះមុខតុលាការអង្គហេតុគឺមានការឆ្លើយបំភ្លឺខុសៗគ្នា និងមិនមានភស្តុតាងដាក់បន្ទុកណាបញ្ជាក់ឱ្យបានជាក់ច្បាស់ឡើយ។ មិនមានភាពស៊ីចង្វាក់គ្នារវាងអង្គហេតុជាមួយនឹងភស្តុតាង រវាងភស្តុតាងនឹងភស្តុតាង និងប្ដឹងសុំឱ្យតុលាការកំពូលបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ និងសុំបង្វិលសំណុំរឿងក្ដីនេះទៅសាលាឧទ្ធរណ៍វិញនោះ គឺជាសេចក្ដីសន្និដ្ឋានមានមូលដ្ឋានលើអង្គហេតុ ភស្តុតាង អង្គច្បាប់ សមស្របតាមបទប្បញ្ញត្តិមាត្រា៣៥១ ត្រង់កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិមាត្រា ៣៨ ត្រង់ចំណុចទី៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា "វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច" ។

៦-យល់ឃើញថា ជនជាប់ចោទទាំង ៤ នាក់ទៀត សុទ្ធតែបានប្រកែកថា ខ្លួនមិនបានប្រព្រឹត្តអំពើសម្លាប់ជនរងគ្រោះឈ្មោះ សំណាង [redacted] សំណាង) ដូចការចោទប្រកាន់ឡើយ។ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញក៏បានផ្ទុះបញ្ចាំងឱ្យឃើញថា រឿងក្ដីនេះស្ថិតក្នុងកម្រិតវិមតិសង្ស័យនៅឡើយ។ វាយតម្លៃជារួមនូវមូលហេតុទាំងអស់ដូចបានលើកបង្ហាញខាងលើនេះ នាំឱ្យតុលាការកំពូលកំណត់បានថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទទាំង ៤ នាក់នេះ ដែលប្ដឹងចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៥ ក្រIV "ណ" ចុះថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ មានមូលហេតុនៃបណ្ដឹងសាទុក្ខដូចមានបញ្ញត្តក្នុងមាត្រា ៩១៤ ត្រង់ចំណុចទី៤ និងចំណុចទី ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជាហេតុតុលាការកំពូលគប្បីសម្រេចបង្វិលសំណុំរឿងក្ដីនេះរបស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះសាឡើងវិញ ។

៧-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣៥ ក្រIV "ណ" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្ដីមកនេះ មិនត្រឹមត្រូវតាមគតិច្បាប់ទេ ។

## ហេតុដូច្នេះ

## សម្រេចសេចក្ដី

១-ទទួលពាក្យបណ្ដឹងសាទុក្ខលេខ ១៤៩ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ថេត , [redacted] អឿន , [redacted] ឡៃន និងឈ្មោះ [redacted] រី ដែលបានធ្វើប្ដឹងសាទុក្ខតាមរយៈមេធាវី [redacted] សីង្ហហេង ជាអ្នកតំណាងក្នុងការប្ដឹងសាទុក្ខ ។



Scanned with CamScanner